«ឯងសុខសប្បាយទេគន្ធា? ខ្ញុំនឹងទៅលេងបាត់ដំបងនៅថ្ងៃសៅរ៍នេះ!»

«និយាយទូរសព្ទជាមួយអ្នកណាក៏សប្បាយចិត្តម្ល៉េះអូន?»

ប្ដីរបស់នាងមកពីក្រោយខ្នង នាងប្រញាប់ឆ្លើយតបវិញភ្លាមថា៖

« គឺ... ធីតា! ធីតាប្រាប់ថា នឹងមកលេងបាត់ដំបងនៅថ្ងៃសៅរ៍នេះ! នឹកឃើញគេដែរអត់?»

«ភ្លេចម៉េច? មិត្តភក្តិអូនទាំងអស់បងនៅចាំ!»

គន្ធាស្រាប់តែលែងមាត់។ ការចងចាំរបស់ប្ដីនាង អំពីបណ្ដាមិត្តភក្តិនាង បានបណ្ដាលឱ្យរឿងចាស់ៗហាក់បីដូចជាចាប់ផ្ដើម លងមកវិញក្នុងអារម្មណ៍។

នឹកដល់ពេលច្រើនឆ្នាំមកហើយ ពួកនាងនៅជំទង់ ថ្ងៃមួយដែលមិត្តភក្តិស្និទ្ធទាំងបីនាក់ គឺធីតា គន្ធានិងដាណេបានធ្វើអំពើម្យ៉ាងទៅលើដូនចាស់ ដែលជាអ្នកថែសួន របស់ស្រីមុំ ។

**ស្អែកឡើង ......**

«មកដល់លឿនណាស់ដាណេ! ម៉ែ! ម៉ែ! ជួយរៀបគ្នា ប្រហែលជា១ម៉ោងអីទៀតហ្នឹងធីតាមកដល់ហើយ»

ដាណេ គឺជាមិត្តម្នាក់ក្នុងចំណោមមិត្តដ៏ជិតស្និទ្ធទាំងបី។ ពួកគេមានស្ថានភាពគ្រួសារជាអ្នកមានដូចគ្នានៅក្នុងខេត្តបាត់ដំបងនេះ។ ឪពុកម្ដាយដាណេ គឺជាដង្ហៅស្រូវមានដេប៉ូទិញលក់ធំរាប់រយតោនជារៀងរាល់ខែ ចំណែកឪពុកម្ដាយរបស់ គន្ធាគឺជាអ្នកលក់ត្បូងដ៏ល្បីម្នាក់ មានទាំងហាងនៅប៉ៃលិនក៏ដូចជាបន្ទាយមានជ័យនិងបាត់ដំបងនេះផ្ទាល់។ រីឯធីតាគឺជាកូនអ្នកភ្នំពេញ។ ពួកគេស្គាល់គ្នាការរៀននៅមហាវិទ្យាល័យនៅភ្នំពេញ។ ពេលនេះកន្លងមកច្រើនឆ្នាំ បីនាក់ស្រីៗមានគ្រួសាររៀងខ្លួនលើកលែងតែដាណេម្នាក់នេះ។

«ប្ដីរបស់គេមកទេ?» ដាណេសួរឡើង។

«អ្នកណា? ប្ដីធីតា? អូអត់ទេ!» គន្ធាឆ្លើយទាំងរៀបចំចានក្បានជប់លៀងទទួលមិត្ត។

«ឮសួរថា ប្ដីគេចេញទៅប្រជុំនៅស្រុកក្រៅបានជាគេមានពេលមកលេងបាត់ដំបង» គន្ធាបន្ត។

«ហើយមកជាមួយនរណា?» ដាណេសួរ។

«ឮសួរថាមកតែម្នាក់ឯងទេ! បើកឡានមកតែឯង!»

«ប្រហែលជាកើតទុក្ខរឿងប្ដីមានស្រីហើយមើលទៅ!»

ឮដាណេចថាបែបនេះគន្ធាបង្អង់ដៃដែលរៀបចាន ហើយងើបមុខមើលទៅលើផ្ទះ។

«ចុះប្ដីឯងនៅដែរ?»

គន្ធាទម្លាក់ទឹកមុខបន្លប់រឿងផ្សេង៖

«រឿងធីតា ពេលគេមកពីឆ្ងាយ ឯងអីហ្នឹង កុំចេះតែថាប៉ប៉ោចតាមនឹកឃើញឮ?»

ហាក់មិនអស់ចិត្ត ដាណេចក្រោកមកក្បែរមិត្តរួចខ្សឹប៖

«នែ៎ កុំថាឯងមិនដឹងណា៎នាង! ឮគេនិយាយច្រើនហើយ ថាប្ដីប្រពន្ធនេះរៀបការដោយបង្ខំចិត្តទេ ពួកអ្នកមាននៅភ្នំពេញតែអ៊ីចឹង!»

គន្ធាបន្លប់ដោយសំណើចចំអករួមទាំងកែវភ្នែកសម្លក់មិត្ត៖

«ហើយពួកកូនដង្កៅជាអ្នកមាននៅបាត់ដំបងវិញអង្កាល់យកប្ដី?»

ត្រូវគន្ធាថាឱ្យ ដាណេចទម្លាក់ទឹកមុខថយមកចុចទូរសព្ទ។ មិនដឹងយ៉ាងម៉េច ឃើញមិត្តបែបនេះ គន្ធាក៏ហាក់មានអារម្មណ៍នឹកឃើញដល់អតីតកាលដែរទម្លាក់ទឹកមុខដូចគ្នា។

**ម៉ោងបួនរសៀល.....**

«អូ! ចម្ការឯងធំណាស់គន្ធា! អាកាសធាតុនៅទីនេះត្រជាក់ស្រួលមែនទែន! អ៊ីចឹងខ្ញុំមិនកក់សណ្ឋាគារទេ!»

«ប្រាប់ហើយថាមកដល់ផ្ទះសេដ្ឋីបាត់ដំបងមួយទាំងមូល កក់សណ្ឋាគារធ្វើអ្វី!» ដាណេចថាឱ្យហើយឆ្លៀតដៀងភ្នែកមើលមកគន្ធាមួយឆ្វាច់ទើបហុចថាសផ្លែឈើមានស្វាយល្មុតនិងក្រូចដែលចិតរួចមកមិត្តអ្នកភ្នំពេញគឺធីតា។

«នែកុំចេះតែថា អ្នកណាសេដ្ឋី? អ្នកនិយាយហ្នឹងដឹង?!» គន្ធាតបតទាំងសប្បាយចិត្តដែលត្រូវបានដាណេចសរសើរទ្រព្យគ្រួសារនាង។

ដាណេចងក់ក្បាល៖

«អូខេៗ ក្រុមនេះទាំងអ្នកបាត់ដំបងនិងអ្នកភ្នំពេញសេដ្ឋីទាំងអស់! បាននៅប៉ុណ្ណឹង?»

ស្រាប់តែសម្ដីនេះធ្វើឱ្យធីតាដែលទើបនឹងមកដល់បាត់ដំបងធ្វើមុខស្ងួតឡើង។ មិនសុខមិនសាប់នាងត្រូវតែនិយាយចេញនូវភាសាក្នុងចិត្ត៖

«នែ៎ ពួកឯង! យើងគិតថា ....ចង់...ទៅលេងស្រីមុំ!»

ពួកគេទម្លាក់ទឹកមុខដៀងភ្នែកមើលមុខគ្នា។

ស្រីមុំ គឺជាមិត្តម្នាក់ដែលរៀនភ្នំពេញជាមួយពួកគេដែរ ប៉ុន្តែក្រោយមកនាងត្រូវបាន បញ្ជូនមកកាន់ខេត្តបាត់ដំបងវិញដោយសារតែមានរបួសធ្ងន់ ។ អតីតគឺជាអតីតតែទំនងជាអតីតមិនល្អសោះ បើមើលលើទឹកមុខគន្ធានិងដាណេ។

**ស្រុកកំរៀងខេត្តបាត់ដំបង....**

«ជម្រាបសួរអ៊ំស្រី ពួកខ្ញុំមកលេងស្រីមុំ!»

ដូនចាស់ ដែលមានវ័យត្រឹម៦០ឆ្នាំមានសក់ស្កូវព្រោងលំបាកលំបិនស្មើមនុស្សវ័យ៨០ប្លាយទៅហើយ។ គាត់ក្រតោកយ៉ាក តែត្រេកអរណាស់ពេលឃើញនារីៗមកពីបាត់ដំបងនិងភ្នំពេញ។

«អូ! ក្មួយគន្ធានាំគ្នាទៅណាមកណាហ្នឹង? តោះៗ! អង្គុយលេងគ្រែឬស្សីនេះសិន!»

មិត្តភក្តិទាំងបីរបស់ស្រីមុំ ធីតាហើយនិងគន្ធានេះ ជាមនុស្សដែលរៀនជាមួយស្រីមុំកាលពីច្រើនឆ្នាំមុនពួកគេកសាងគ្រួសារតែអ៊ំស្រីស្គាល់ច្បាស់តែគន្ធាទេ។

«ហើយ....ពីរនាក់ទៀតដែលនៅចាំក្បែរឡានហ្នឹង ម៉េចក៏មិនចូល?!»

គន្ធាងាកទៅឃើញដាណេឈរមុខស្លេកនៅក្បែរឡានរបស់ធីតា។

នាងដឹងថាមានអ្វីកើតឡើង ប៉ុន្តែធ្វើជាស្រែកហៅដូចធម្មតា៖

«នែ៎ឡានហ្នឹងអត់អ្នកណាយកទេ! មិនបាច់ភ័យ! នាំគ្នាចូលមក!»

ថាហើយក៏គន្ធាសង្រួមធ្វើសុភាពរាបសារងាកមកសម្លឹងអ៊ំដែលអង្គុយលើគ្រែ។

ទឹកមុខនិងសភាពក្រលំបាករបស់គាត់ នាងក៏ឈ្ងោកពិបាកចិត្ត។

«ស្រីមុំបានអាការៈធូរទេអ៊ំ?»

«នៅតែដដែល!»

គាត់តបខ្លី ភ្នែកសម្លឹងទៅឆ្ងាយ ធ្វើមុខស្ងួត ។

គន្ធាតឹងទ្រូងស្ទើរប្រេះ នាងទាញដៃធីតាដែលមកដល់ឱ្យឡើងអង្គុយ ខណៈដាណេអង្គុយបែរខ្នង ។

«ពួកខ្ញុំមកនេះ មិនបានចូលទៅលេងស្រីមុំទេព្រោះមិនចង់ឃើញសភាពរបស់គេ ប៉ុន្តែ...មានប្រាក់កាសខ្លះ បានចូលគ្នាយកមកជូនអ៊ំស្រីដោះស្រាយជីវភាព!»

អ៊ំរលីងរលោង សម្លឹងមកស្រោមសំបុត្រពេញដោយលុយធូន់កណ្ដុក។

គាត់ទទួលយកទាំងទឹកភ្នែកមិនភ្លេចលើកដៃប្រណមឱ្យពរឱ្យជ័យ។

«គិតទៅ! អាមុំ សំណាងត្រង់បានក្មួយទាំងបីជាមិត្តភក្តិ! រូបស្អាតនិងចិត្តល្អណាស់ ប៉ុន្តែ....ហ៊ឹម » គាត់ជូតទឹកភ្នែក។

«ស្រីមុំគ្មានសង្ឃឹមនោះទេ!»

គាត់បន្ថែមមកធ្វើឱ្យម្នាក់ៗតឹងទ្រូងដកដង្ហើមមិនចង់ចេញ។

**រឿងហេតុកាលពីប្រាំឆ្នាំមុន**

«ស្រីមុំឯង ទៅណាក៏ប្រញាប់ប្រញាល់ម្ល៉េះ?» ដាណេក្រពាត់ដៃសម្លឹងស្រីមុំពីលើក្បាលដល់ចុងជើង ទាំងមុខក្រញូវ ទុកឱ្យគន្ធជាអ្នកសួរចម្លើយ។

«អត់! អត់មាន....អត់មានទៅណាផង! ទៅផ្ទះជួលវិញហ្នឹង!»

«កុហក!» ធីតាស្រែកសម្លុតមកពីក្រោយខ្នង។

«សូម្បីអ្នកណាផ្ញើផ្កាកុលាបមកឯងស្មានថាយើងមិនដឹង?!» ធីតាថាបន្ថែមទាំងមុខក្រញូវច្រណែន។

«មានឯណា?» ស្រីមុំក្រហមមុខងាំងជាកាយវិកាសារភាពស្រេចទៅហើយ នេះធ្វើឱ្យគន្ធាខឹងនិងចង្អុលមុខ៖

«មនុស្សកុហកដូចឯង យើងស្អប់បំផុតនាងមុំ!»

«កុំខឹងមើល» មុំអង្វរ។

«មកពីយើងមិនទុកថាជាការពិត!»

គន្ធាខាំមាត់សង្ស៊ើញសួរខ្សឹបៗ៖

«គឺម្នាក់នោះមែនទេ ? កូនប្រុសអ្នកមានដែលមកពីកំពង់សោម !»

អស់តម្រិះគេចវេះ មុំក៏ឆ្លើយតាមត្រង់៖

«ហ្នឹង...ហើយ ប៉ុន្តែ....កុំយកជាការពិតអីគន្ធា! ប្រុសម្នាក់នោះគេលេងសើចទេ ខ្ញុំក៏មិនខ្វល់ជាមួយគេដែរបានជាមិននិយាយប្រាប់ពួកឯង!»

មុំមិនដឹងទេថា ការដែលនាងត្រូវបានប្រុសស្អាតនិងមានជាងគេក្នុងថ្នាក់តាមញ៉ែឱ្យផ្កា បានធ្វើឱ្យជើងកាងស្រីកូនអ្នកមានទាំងបីខឹងច្រណែនពន់ពេក។

គន្ធាក្រពាត់ដៃសម្លក់ ធីតាក៏ជួយនិយាយឡើង៖

«កុំបានចិត្តពេក! ឈ្មោះដេវីតនោះ គឺជាប្រុសស្អាតក្នុងសាលាដែលស្រីៗជាច្រើនសុទ្ធតែចង់បាន»

«ប៉ុន្តែយើងមិនចង់បានគេទេ ព្រោះយើងជាកូនអ្នកក្រហើយមកពីខេត្តទៀត!»

«គេក៏មកពីខេត្ត សំខាន់គឺទាក់ទងឯង!» ធីតាគំហក។

«មិនដឹងទៅញ៉ែងញ៉ងដាក់គេម៉េចខ្លះផងទេ! ឈែតទៅគេមុនផងមិនដឹង?!»

ដល់វគ្គខឹងនិងធុញ ស្រីមុំកៀសពួកគេចេញ។

«បានហើយ! ខ្ញុំមិនយល់រឿងហ្នឹងទេ! ធីតា និងគន្ធាឯង ចង់ដឹងអ្នកណាញ៉ែ អ្នកណាឈែតម៉េចមិនទៅសួរគេមុនទៅ ?»

ប្រុសស្អាតដេវីត និស្សិតមកពីកំពង់សោម គេជាកូនចៅកែសណ្ឋាគារនិងកាស៊ីណូ។ ហេតុផលដែលគេតាមស្រលាញ់ស្រីមុំ បានត្រូវបែកធ្លាយពេញសាលាធ្វើឱ្យធីតា ដាណេនិងគន្ធាមិនសប្បាយចិត្តជាខ្លាំង ។

ធីតាខ្សឹបដាក់គន្ធានិងដាណេ៖

«ឯងដឹងទេ មានគេខ្សឹបប្រាប់ខ្ញុំថាយប់មិញពួកវាទៅមើលកុនជាមួយគ្នា! នាងស្រីមុំនេះ នៅមុខក្រាស់ចូលចិត្តនិយាយកុហកណាស់!»

ពួកគេបានដឹងថា ចិត្តគ្រប់គ្នាច្រណែនស្រីមុំ តែគ្មានអ្នកណាដឹងទេថា គន្ធាលួច សម្គាល់ស្រឡាញ់ដេវីតស្ទើរឆ្កួតទៅហើយ ។

«ខ្ទិលស្តាប់ណាស់! កុំនិយាយរឿងនាងស្រុកកំរៀងហ្នឹងទៀតអញមិនចង់ឃើញមុខវាទេ!»

គន្ធាជ្រែកពួកគេនិងដើរចេញទៅទាំងមុខក្រហមង៉ូវ។ ដាណេបានចិត្តក៏ញាក់ចិញ្ចើមស៊ីញ៉ូធីតាហើយនិយាយខ្សឹប៖

«ចេញមុខមកបាត់! ដឹងស្រេចអ្នកដែលលួចស្រឡាញ់គេស្ទើរឆ្កួត តាមពិតនៅក្បែរនេះសោះ!»

ធីតាតាមពិតក៏ស្រលាញ់ដេវីត តែធ្វើជាមិនមានចិត្តហើយងាកមកសួរ៖

«ចុះឯងដាណេ? ស្រលាញ់ទាយាទសណ្ឋាគារដែរ?»

ដាណេសម្លក់មិត្ត៖

«ទាយាស្អី? មើលកុនភាគជិតឆ្កួតហើយឯងនេះ! អញក្រណាស់? ខ្លាចអត់សង្សារទៀតនៀក!»

ថាហើយរលាស់ខ្លួនដើរចោលមិត្តទាំងគំរោះគំរើយតែ ធីតារត់តាមៈ

«នែនាង! តោះ! ឱបដៃមើលនាងគន្ធា ចាត់ការនាងមុំរបៀបណា?»

«អាប្រុសហ្នុងភ្នែកស្អុយណាស់! ប៉ុនគន្ធាហើយ មិនយកភ្នែកមើលសោះ សមគេខឹងមែន!»

ដាណេតបហើយពួកគេងាកមកសម្លឹងគ្នាជាមួយកលល្បិចម្យ៉ាងយ៉ាងជ្រៅ។

**បច្ចុប្បន្ននៅតែលងដោយអតីត**

«យប់នេះ ម៉េចក៏បានមិត្តមកលេងហើយ មិនគេងលក់ នៅសំងំគិតអី?»

ត្រូវប្ដីសួរ គន្ធាដែលប្រែខ្លួនចុះឡើងជានិច្ចនោះ នៅស្ងៀមដកដង្ហើមធំ។

«ស្មានថាចួបមិត្តចាស់មិនសូវស្រ្គស!»

ប្ដីរអ៊ូហើយបែរខ្នងគេង។

ស្រាប់តែគន្ធាពោលខ្សឹបពីក្រោយខ្នងៈ

«បងដេវីដ ថ្ងៃមិញពួកយើងបានទៅកំរៀងមើលម្ដាយស្រីមុំ!»

ប្ដីស្ងាត់សឹងឈប់ដកដង្ហើម។

ដេវីដថគឺមិនស្គាល់ អតីតសង្សារដែលខ្លួនតាមស្រលាញ់កាលពីយុវវ័យ។ គេទម្លាក់ទឹកមុខសំងំលាក់បាំងអាថ៌កំបាំងផ្លូវចិត្តខណៈដែលចាប់ផ្ដើមយល់ថាហេតុអ្វីយប់នេះ គន្ធាដេកមិនលក់?

«នៅអាណិតអតីតសង្សារហ្មេន?»

«កុំយករឿងអីចឹងៗមកនិយាយលេងគន្ធា ដេកទៅ!»

ដេវីដបានមករៀបការជាមួយគន្ធាដោយសារតែហេតុផលសម្ងាត់មួយ ប៉ុន្តែគ្មាននរណាដឹងថាការពិតយ៉ាងណាទេ។

«អូនដឹងថា បងតែងតែលបធ្វើលុយតាមរយៈ គេឯងឱ្យទៅម្ដាយរបស់ស្រីមុំ!»

នាងនិយាយស្ងាត់ៗតែបេះដូងដេវីដលោតញាប់។

«អូនមិនបន្ទោសទេ!»

«ត្រូវហើយ! របួសមួយហ្នឹងធ្វើឱ្យស្រីមុំក្រោកឡើងលែងរួចជារៀងរហូត នៅប្រចណ្ឌអី?»

«មិនប្រចណ្ឌតែពិបាកចិត្ត!»

ប្តីនៅស្ងៀម ប្រពន្ធក៏ឱប ពីក្រោយហើយរអ៊ូរង៉ូវៈ

«ស៊ូអាមុំស្លាប់ហ្មងទៅ ល្អជាងនៅវេទនាភ្នែកពួកយើង!»

ស្រាប់តែប្តីមិនមាត់ក៏ដេកស្រម៉ុកខុលដូចមុននេះមិនបាននិយាយគ្នា? ដេរីតដេកលក់បានឆាប់ពេកហើយ ក្នុងគំនិតឆ្ងល់របស់គន្ធា។

«បង?»

ប្រពន្ធនេះខំហៅ តែគេនៅដេកស្កប់និងមានដង្ហើមសុខស្រួល។ គន្ធាកាន់តែចម្លែក។ មិនសមទេ! ពួកគេទើបនឹងជជែកដល់រឿងស្មុគស្មាញកាលពីអតីតចំណងស្នេហាត្រីកោណដែលជាតិនេះមិនងាយនឹងបំភ្លេចបាន ម្តេចដេកលក់បានស្រួលម្លេះ?

«បងដេវីដ!»

ហៅទៀតនៅតែមិនឆ្លើយចង់ងាកមកវិញឱបដៃដេកដែរ ស្រាប់តែ ..... អ្នកណាម្នាក់អង្គុយនៅជើងក្បែរគ្រែបែរខ្នង ធ្វើឱ្យ គន្ធាស្រែកភ្លាត់សំឡេង.....

ដេវីដភ្ញាក់ស្ទុះក្រោកឡើងសើងមមើង.....

«ស្អី? ស្អីគេ?»

«អ្នកណា? មានអ្នកអង្គុយនៅនោះ!»

នាងបិទភ្នែកចង្អុល ធ្វើឱ្យប្តីតាមសម្លឹង!

ស្អីគេគន្ធា? នៅហ្នឹងគ្មានទេ! គ្មានអ្នកណាទាំងអស់!

(នៅមានត)